ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***************

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៨២៦ / ១៥.១០.២០១០

សាលដីកា

លេខ: ៨៤ ក្រ.III.ស/២៦.១០.២០១២

# តាមនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៨២៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ រវាង ៖

ជនជាប់ចោទឈ្មោះ [redacted] ទីន ហៅ គុងទីន ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរៈធ្វើស្រែ ទីលំនៅកំណើត និងទីលំនៅមុនចាប់ខ្លួន [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន។

មេធាវីការពារលោកស្រី [redacted] ម៉េងអ៊ាម។

<u>ជាប់ចោទពីបទ:</u> ការនាំចេញដោយមិនស្របច្បាប់សម្រាប់ការឆ្លងដែន ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**ដំណើររឿងមានដូចតទៅ ៖**

កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង១១ និង៣០នាទី នៅរាជធានីភ្នំពេញ មានករណីការនាំចេញដោយមិនស្របច្បាប់សម្រាប់ការឆ្លងដែនមួយកើតឡើង ដែលបង្កដោយជនល្មើសឈ្មោះ [redacted] ទីន

បាននាំមនុស្សចំនួន១២នាក់ ពីស្រុកកំចាយមារ ខេត្តព្រៃវែង ទៅធ្វើការជាកម្មករនេសាទនៅប្រទេសថៃ ដោយមានឈ្មោះ រិន ជាអ្នកនាំឆ្លងដែនចូលប្រទេសថៃតាមច្រកម៉ាឡៃ តែនាំមកដល់រាជធានីភ្នំពេញ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង, ចំពោះកម្មករទាំង១២នាក់ ឈ្មោះ [redacted] ទីន នាំទៅធ្វើការជាមួយថៅកែឈ្មោះ [redacted] ឃីត។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨៤ កបត «ទ» ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសៈ

ក. ឈ្មោះ [redacted] ប្រុស ហៅ តុងទីន ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៧ (ប្រាំពីរ) ឆ្នាំ។

ខ. ឈ្មោះ [redacted] យឿត ហៅ រិន ភេទប្រុស អាយុ៣០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៧ (ប្រាំពីរ) ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបានយកមកទទួលទោស។

ពីបទ ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០៩ តាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២- សាលក្រមនេះ ជំនុំជម្រះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ទីន ហៅ តុងទីន, មេធាវីការពារជនជាប់ចោទ និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] យឿត ហៅ រិន, បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ទីន ហៅ តុងទីន ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៤ កបត «ទ» ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ជនជាប់ចោទឈ្មោះ [redacted] ទីន ឆ្លើយថា កាលពីឆ្នាំ២០០៧ ខ្លួនបានទៅធ្វើការនេសាទនៅប្រទេសថៃជាមួយ និងប្អូនរបស់ខ្លួនឈ្មោះ [redacted] វ៉ាន់, លុះដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ខ្លួនបានសុំថៅកែឈ្មោះ [redacted] ឃីត មកលេងស្រុក, ពេលនោះ ថៅកែបានប្រាប់ខ្លួនថា បើមានគេចង់មកធ្វើការជាអ្នកនេសាទ ឲ្យខ្លួននាំមក។ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ខ្លួនត្រឡប់ទៅប្រទេសថៃវិញ មានបងប្អូនជាអ្នកស្រុកចំនួន១២នាក់បានសុំខ្លួនទៅធ្វើការនេសាទជាមួយខ្លួន, ខ្លួនក៏បាននាំពួកគេទៅម៉ាឡៃ ដើម្បីឲ្យឈ្មោះ នាំទៅប្រទេសថៃ។ ក្នុងការនាំ ៖

ពួកគេទៅថៃនេះ ឈ្មោះ រិន បានយកប្រាក់ពីពួកគេក្នុងម្នាក់ៗចំនួនពីរពាន់បាត, ចំណែកខ្លួនយកតែចំនួនម្ភៃម៉ឺនរៀលទេ ដើម្បីដោះស្រាយដំណើរ ខ្លួនបាននាំពួកបងប្អូនទាំង១២នាក់នោះមកដល់ភ្នំពេញ ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង។ ក្នុងការនាំបងប្អូនទាំងអស់នេះ ទៅធ្វើការនៅប្រទេសថៃនេះ ខ្លួនពុំបានលួងលោមអូសទាញពួកគេទេ គឺពួកគេសុំឲ្យខ្លួនជួយនាំពួកគេទៅធ្វើការ។ សំណូមពរ សុំបន្ធូរបន្ថយទោសឲ្យខ្លួនផង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

រឿងនេះជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តអញ្ចឹងមែន សុំក្រុមប្រឹក្សា ពិនិត្យ និងសម្រេចទៅតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

សុំក្រុមប្រឹក្សាពិចារណា ក្នុងរឿងនេះ សាលាដំបូងបានសម្រេចផ្តន្ទាទោសកូនក្តីខ្លួន ចំនួនប្រាំពីរឆ្នាំ តាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឃើញថាមិនសមស្របទេ ព្រោះមនុស្សដែលកូនក្តីខ្លួននាំទៅនេះជាបងប្អូនគាត់ ហើយពួកគាត់គឺមានបំណងចេញទៅធ្វើការនៅប្រទេសថៃ ចំពោះប្រាក់ដែលកូនក្តីខ្លួនបានទទួលចំនួនម្ភៃម៉ឺនរៀល ក្នុងម្នាក់ៗ នោះជាថ្លៃដឹកនាំធ្វើដំណើរ មិនមែនជាប្រាក់កំរៃសំរាប់ផ្តល់ដល់កូនក្តីខ្លួននោះទេ, សូមក្រុមប្រឹក្សាមេត្តាធ្វើការលើកលែងចោទប្រកាន់ដល់រូបកូនក្តីខ្លួនដោយអនុគ្រោះ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ទីន,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ

## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ទីន ហៅ គុងទីន ជាជនជាប់ចោទ ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយជនជាប់ចោទថា កាលពីឆ្នាំ២០០៧ ខ្លួនបានទៅធ្វើការនេសាទ នៅប្រទេសថៃជាមួយ និងប្អូនរបស់ខ្លួនឈ្មោះ [redacted] ភ៉ាន់, លុះដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ខ្លួនបានសុំថៅកែឈ្មោះ [redacted] ឃីត មកលេងស្រុក, ពេលនោះ [redacted] ឃីត បានប្រាប់ខ្លួនថា បើមានគេចង់មកធ្វើការជាអ្នកនេសាទ ឲ្យខ្លួននាំមក។ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ខ្លួនត្រឡប់ទៅប្រទេសថៃវិញ មានបងប្អូនជាអ្នកស្រុកចំនួន១២នាក់ បានសុំខ្លួនទៅធ្វើការនេសាទជាមួយខ្លួន, ខ្លួនក៏បាននាំពួកគេទៅម៉ាឡៃ ដើម្បីឲ្យឈ្មោះ នាំទៅប្រទេសថៃ។ ក្នុងការនាំពួកគេទៅថៃនេះ ឈ្មោះ រិន បានយកប្រាក់ពីពួកគេក្នុងម្នាក់ៗចំនួន ២.០០០បាត, ចំណែកខ្លួនយកតែចំនួន ២

២០០.០០០៛ (ម្ភៃម៉ឺនរៀល) ទេ ដើម្បីដោះស្រាយដំណើរ ខ្លួនបាននាំពួកបងប្អូនទាំង១២នាក់នោះមកដល់ភ្នំពេញ ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង។ ក្នុងការនាំបងប្អូនទាំងអស់នេះ ទៅធ្វើការនៅប្រទេសថៃនេះ ខ្លួនពុំបានលួងលោមអូសទាញពួកគេទេ គឺពួកគេសុំឲ្យខ្លួនជួយនាំពួកគេទៅធ្វើការ។

៣. មានភស្តុតាងបញ្ជាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទ ការនាំយកចេញដោយខុសច្បាប់សម្រាប់ឆ្លងដែន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ តាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

៤. សាលក្រមព្រហ្មទណ្ឌលេខ ៨៤ កប៣ «ទ» ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១០ របស់ឈ្មោះ [redacted]ទីន ហៅ តុងទីន ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៤ កប៣ «ទ» ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

៣. បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ, បើកផ្លូវតវ៉ាតាមច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ ៜ**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា[redacted] [redacted] | ហត្ថលេខា: [redacted] |

..............................................................................................................

| | |
|---|---|
| បានឃើញ | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
| ប្រធានសាលាឧទ្ធរណ៍ | ភ្នំពេញ, ថ្ងៃទី ០៤ ខែ ៦..... ឆ្នាំ ២០១៤ |
| [redacted] | ក្រឡាបញ្ជី |